អ៊ិនធើណេសិនណល ស្គូល អហ្វ សៀមរាប
International School of Siem Reap

ព័ត៌មានពីនាយិកាសាលាបឋមសិក្សា
ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧
វ៉ុល:០២
លេខៈ ៣

# ព័ត៌មានពីនាយិកាសាលាបឋមសិក្សា

## កម្មវិធីបណ្ណាល័យសិក្សា

កម្មវិធីបណ្ណាល័យសិក្សារបស់សាលាចាប់ផ្ដើមហើយ ពិសេសមានការរៀបចំនូវសកម្មភាពប្លែកៗជាច្រើនដែលជំរុញឱ្យសិស្សានុសិស្សកាន់តែមានចំណាប់អារម្មណ៍លើការអានសៀវភៅក្នុងបណ្ណាល័យរបស់សាលា។ សិស្សនឹងតម្រូវឱ្យអានសៀវភៅរឿង ដោយបញ្ចេញសម្លេងខ្លាំងៗ សិស្សទាំងអស់នឹងអនុវត្តន៍បែបនេះមួយរយៈ រហូតទាល់តែពួកគេមានទំនុកចិត្តក្នុងការអានសៀវភៅ។ ក្រុមសិស្សនីមួយៗនឹងរៀបចំឱ្យមានការប្រកួតប្រជែងក្នុងការអាន ហើយសម្រាប់អ្នកដែរធ្វើបានល្អនឹងត្រូវបានបន្តទៅដល់វគ្គផ្ដាច់ព្រ័ត្រ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រទី២០ ខែតុលា។ នាងខ្ញុំជូនពរសិស្សទាំងអស់ឱ្យជួបតែសំណាងល្អគ្រប់ៗគ្នាលើការប្រកួតប្រជែងនេះ។ បច្ចុប្បន្នសាលាកំពុងធ្វើការប្រមែប្រមូលសៀវភៅដើម្បីបរិច្ចាគដល់មជ្ឈមណ្ឌលសហគមន៍ផ្ទះ Grace House (http://www.gracehousecambodia.org/programs.php) ដែលជាកន្លែង ជួយដល់កុមារជាច្រើននៅក្នុងខេត្តសៀមរាប ពិសេសការថែទាំកុមារ នឹងជួយគ្រួសារកុមារពិការផងដែរ។ ក្មេងៗជាច្រើននៅទីនោះនឹងសប្បាយចិត្ត ពេលទទួលបានសៀវភៅដែលយើងបរិច្ចាគឱ្យពួកគេ។



សិស្សថ្នាក់ Rec1 B កំពុងសប្បាយរីករាយ សិក្សាអំពីរូបរាងកាយ ដោយប្រើថ្នាំពណ៌ លាបជាមួយគ្នាដើម្បី បង្ហាញពីរូបភាព។

ព្រមជាមួយគ្នានេះដែរ នាងខ្ញុំសូមថ្លែងអំណរគុណដល់លោក/លោកស្រី មាតាបិតា និងអាណាព្យាបាលសិស្សដែលបានស្ម័គ្រចិត្តចូលរួមអានសៀវភៅជាមួយកូនៗរបស់លោកអ្នក នៅក្នុងថ្នាក់។ សិស្សទាំងអស់គ្នាមានការរំភើបព្រមទាំងទន្ទឹងរង់ចាំការចូលរួមរបស់លោក/លោកស្រី។
ប្រសិនបើលោក/លោកស្រីមានចំណាប់អារម្មណ៍ចង់ចូលរួមដោយស្ម័គ្រចិត្ត សូមទំនាក់ទំនងមកការិយាល័យរដ្ឋបាលសាលា។

## កម្មវិធីទំនាក់ទំនងតាមប្រពន្ឋ័ ដូចូ (Dojo)

កម្មវិធីទំនាក់ទំនងតាមប្រពន្ធ័ដូចូ (Dojo) របស់សាលាគឺមានការចូលរួមពីសំណាក់លោក/លោកស្រីចំនួន ១១០គ្រួសារក្នុងពេលបច្ចុប្បន្ននេះ។ លោកគ្រូ/អ្នកគ្រូមានសកម្មភាពផ្សេងៗក្នុងថ្នាក់រៀន ហើយថតរូបពីសកម្មភាពក្នុងថ្នាក់ដែលសិស្សទាំងអស់បានកំពុងតែសិក្សាជាមួយមិត្តភ័ក្តិនឹងលោកគ្រូ/អ្នកគ្រូ។ ដើម្បីទទួលបានរូបភាពនឹងសកម្មភាពសិក្សារបស់កូនៗ សូមលោក/លោកស្រីចូលរួមបង្កើតគណនេយ្យមួយ (Signed up) ផ្ទាល់ខ្លួនក្នុងការចូលរួម។ សូមលោក/លោកស្រីយកលេខកូដពីលោកគ្រូ អ្នកគ្រូបន្ទុកថ្នាក់ដើម្បីចូលទៅក្នុងកម្មវិធី ដូចូ។



## ការរួបរួមជាធ្លុងមួយរបស់ ISSR

សាលា **អ៊ិនធើណេសិនណល អហ្វសៀមរាប** គឺជាគ្រួសារមួយដែលរួបរួម និងមានការសហការយ៉ាងជិតស្និតជាមួយគ្រប់បុគ្គលិកទាំងអស់។ បច្ចុប្បន្នកាល សាលាកំពុងតែពង្រឹងភាពស្និតស្នាលយ៉ាងជិតស្និតជាមួយនឹងអាណាព្យាបាលសិស្សានុសិស្ស គ្រប់បុគ្គលិកឱ្យមានការគួរសម ចេះគោរព ព្រមទាំងឲ្យតម្លៃគ្នាទៅវិញទៅមក។ បុគ្គលិកគ្រប់រូប ដែលធ្វើការនៅសាលារៀន ISSR ពួកគេខិតខំប្រឹងប្រែងធ្វើការយ៉ាងខ្លាំងដើម្បីធានាឱ្យបាននូវសុខភាព សុត្ថិភាព ភាពងាយស្រួលដល់កូនៗរបស់លោក/លោកស្រី។ ដូចនេះ នាងខ្ញុំសំណូមពរលោក/លោកស្រី ដែលជាមាតាបិតា អាណាព្យាបាលសិស្សទាំងអស់ឱ្យមានការគោរពនិងឱ្យតម្លៃដល់បុគ្គលិកទាំងអស់របស់សាលាអន្តរជាតិ ISSR។ ការគោរពនឹងនិយាយពិរោះគឺ ជាឧទាហរណ៍ ដែលយើងតែងតែផ្ដល់ជាគំរូល្អដល់សិស្សានុសិស្សជារៀងរាល់ថ្ងៃ។ នាងខ្ញុំសូមទទួលស្គាល់ និងគោរពចំពោះមាតាបិតាដែលតែង តែមានការគោរពនិងប្រើប្រាស់ពាក្យពេជន៍ល្អៗទៅកាន់កូនៗ ព្រមទាំងដល់អស់បុគ្គលិករបស់សាលាអន្តរជាតិយើងខ្ញុំ។ ដោយសាលាអន្តរជាតិ ISSR គឺធ្វើការជាធ្លុងមួយ ដូចនេះនាងខ្ញុំនឹងខិតខំឱ្យបុគ្គលិកទាំងអស់បន្តការធ្វើជាគំរូល្អយ៉ាងខ្ជាប់ខ្ជួន ហើយនាងខ្ញុំសង្ឃឹមថាលោក/លោកស្រតែងតែជួយសហការក្នុងកិច្ចការទាំងនេះផងដែរ។



សិស្សថ្នាក់ Reception 2A កំពុងបង្ហាញ ជំនាញបង្វិលកងរបស់ពួកគេក្នុងម៉ោងសម្រាក បរិវេណខាងក្នុងសាលា។

*We are one,*
*But we are many.*



សិស្សថ្នាក់ Rec2A កំពុងសប្បាយរីករាយសិក្សាអំពីការបង្ហាញពីរូបភាព 2D និង 3D។

## កម្មវិធីបុណ្យហាឡូវីន (Halloween)

កម្មវិធីបុណ្យហាឡូវីននឹងរៀបចំឡើងក្នុងថ្ងៃអង្គារទី៣១ ខែតុលា ឆ្នាំ២០១៧ ខាងមុខនេះ សាលានឹងរៀបចំឱ្យមានការដង្ហែរហាឡូវីនប្រចាំឆ្នាំក្នុងបរិវេណសាលា។ សិស្សទាំងអស់បានត្រៀមការតុប តែងដ៏ភ្ញាក់ផ្អើលរបស់ពួកគេក្នុងថ្ងៃនោះ។ សូមសិស្សានុសិស្សទាំងអស់តុបតែងខ្លួនដើម្បីចូលរួមក្នុង ពិធីបុណ្យ Halloween នៅសាលា និងចូលរួមវិភាគទានចំនួន ១ដុល្លារ (ស្ម័គ្រចិត្ត) ដើម្បីប្រមូលថវិកាជួយដល់មន្ទីរ ពេទ្យ កុមារអង្គរ និងមន្ទីរពេទ្យគន្ធបុប្ផាអង្គរសម្រាប់កិច្ចការមនុស្សធម៌។

ចំពោះការតុបតែងក្នុងកម្មវិធី Halloween និងមានរង្វាន់សម្រាប់អ្នកដែលតុបតែងមានភាពទាក់ទាញខ្លាំងជាងគេ។ រង្វាន់ទាំងនេះនឹងបែងចែកទៅតាមក្រុមតំណាងឆ្នាំនីមួយៗដូចជា៖ ថ្នាក់មូលដ្ឋាន (ថ្នាក់ Nursery ដល់ថ្នាក់ Rec2), ក្រុម Key Stage1 (ថ្នាក់ទី១ ដល់ថ្នាក់ទី២), ក្រុម Key Stage 2 (ថ្នាក់ទី៣ ដល់ថ្នាក់ទី៦)។ ចំពោះថ្នាក់ទី៦ នឹងមានការ រៀបចំតុបតែងមុខមាត់ មុនកម្មវិធីចាប់ផ្តើម។



សិស្សថ្នាក់ទី ៣B កំពុងបង្ហាញការសិក្សា អំពីខែល (គ្រឿងសមយុទ្ធ) ដែលជាប្រធានបទអំពីប្រវត្តិសាស្ត្រ ក្នុងរជ្ជកាល Vikings.

## ប្រកួតកីឡាវាយសី (Badminton Tournament)

នៅពេលថ្មីៗកន្លងទៅនេះសិស្សថ្នាក់ទី៦ បានចូលរួមការប្រកួតកីឡាវាយសី ដែលត្រូវបានធ្វើឡើងនៅតារាងកីឡាដ្ឋានជន្លង់ (Chun Lung Sports Centre)។ ព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងដើម្បីលើកទឹកចិត្តដល់អ្នកចូលរួមជាជាងការប្រកួតប្រជែង ប៉ុន្តែសិស្សានុសិស្សទាំងអស់អាចបង្ហាញពីជំនាញ និងសមត្ថភាពដ៏ប៉ិនប្រសប់របស់ពួកគេ។ សិស្សានុសិស្សមានមោទនភាពក្នុងការធ្វើជាតំណាងឲ្យសាលារៀន ប្រកបដោយក្តីរីករាយ ការចូលលេងមានការគោរពគ្នាទៅវិញទៅមក មានវិន័យនៅពេលប្រកួតប្រជែង ពិសេសជាមួយសាលារៀនដទៃទៀត។ ការប្រកួតបន្ទាប់ គឺកីឡាលេងអុក តែសូមសិស្សានុសិស្សទាំងអស់ សាកសួរព័ត៌មានពីលោកគ្រូ Robert ដើម្បីទទួលបានព័ត៌មានបន្ថែម។

## ការពាក់ស្បែកជើងសមរម្យមកសាលារៀន

ការពាក់ស្បែកជើងឱ្យបានត្រឹមត្រូវគឺជាចំណែកមួយនៃឯកសណ្ឋានសាលា សិស្សទាំងអស់ត្រូវតែពាក់ស្បែកជើងសមរម្យពេលមកសាលារៀន។ ស្បែកជើងសមរម្យ យ៉ាងហោចណាស់ត្រូវគ្របកែងជើងកូនៗលោក/លោកស្រី ទើបពួកគេមានសុវត្ថិភាពនៅពេលរត់លេង។ លក្ខខណ្ឌនេះ សិស្សទាំងអស់ត្រូវតែគោរពតាម ពីព្រោះការពារសុវត្ថិភាពជើងរបស់កូនៗ ទាំងពេលលេងនិងពេលញ៉ាំបាយ។ ដូចនេះប្រសិនបើសិស្សានុសិស្សទាំងអស់មកសាលាហើយមិនបានពាក់ស្បែកជើងសមរម្យ (មិនគ្រប់កែងជើង) ពួកគេនឹងត្រូវឱ្យអង្គុយ នៅនឹងកន្លែងលេងខាងក្រៅ មិនអនុញ្ញាតឱ្យរត់លេងរហូតដល់ពួកគេមានស្បែកជើងសមរម្យ និងមានសុវត្ថិភាពទើបអាចឱ្យរត់លេងបាន។ ហើយសាលាក៏នឹងផ្ញើលិខិតជូនដំណឹងទៅលោក លោកស្រី មាតាបិតា អាណាព្យាបាលអំពីការពាក់ស្បែកជើងសមរម្យនៅសាលារៀនជ្រាបជាព័ត៌មានផងដែរ។




*__ចំណាំ៖__ ត្រូវយកម្ហូបអាហារណាដែលមានសុខភាពល្អមកសាលារៀងរាល់ថ្ងៃ!*




សាលានឹងធ្វើការឈប់សម្រាកដើម្បីចូលរួមកម្មវិធីបុណ្យអុំទូកប្រពៃណីយជាតិ
<u>នៅថ្ងៃ**ព្រហស្បតិ៍ ទី០២-០៣ ខែវិច្ឆិកា** ឆ្នាំ២០១៧ ហើយចាប់ផ្តើមចូលរៀនវិញនៅថ្ងៃ**ចន្ទទី០៦ ខែវិច្ឆិកា**ឆ្នាំ២០១៧។</u>
សូមលោក/លោកស្រី ដែលជាមាតាបិតា និងអាណាព្យាបាលសិស្សទាំងអស់រីករាយក្នុងពិធីបុណ្យអុំទូកខាងមុខ!

**<u>ការរៀបចំ Star of the Month៖</u>**
ការរៀបចំ Star of the Month ខែក្រោយគឺចាប់ផ្តើមពីម៉ោង ៨:០០ព្រឹក៖
- ថ្ងៃអង្គារ៍ ទី០៧ ខែវិច្ឆិកា - ថ្នាក់ **Nursery** និង**Year 1** (ថ្នាក់ R2A សម្តែង)
- ថ្ងៃពុធ ទី០៨ ខែវិច្ឆិកា - ថ្នាក់ទី២ និងទី៦ (ថ្នាក់ទី២A សំម្តែង)

សិស្សទាំងអស់រងចាំការសំដែងនេះដោយក្តីរំភើបរីករាយដល់លោក/លោកស្រី!

សេវាកម្មមើលថែកូនៗពេលរសៀល ថ្នាក់Reception 1 និងថ្នាក់ Nursery បានកំពុងតែចាប់ផ្តើមហើយ។ ប្រសិនបើលោក-លោកស្រីមានចំណាប់អារម្មណ៍ការថែទាំពេលរសៀលសូមធ្វើការទំនាក់ទំនងមកកាន់ការិយាល័យរដ្ឋបាលសាលា។